**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.........✓.........ន. គ. ស ......

ថ្ងៃចន្ទ ៣រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការពន្យារពេលក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ**

**និយ័តករគណនេយ្យនិងសវនកម្ម** នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងសិក្ខាកាមទាំងអស់ដែលបានចុះឈ្មោះចូលរួមសិក្សា វគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ មេត្តាជ្រាបថា៖ វគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលនឹងត្រូវរៀបចំនៅថ្ងៃទី២៦-២៧-២៨ ខែមិថុនា ឆ្នាំ២០២៤ ត្រូវបានពន្យារពេល ដោយហេតុថា **និយ័តករគណនេយ្យនិងសវនកម្ម** ចង់ផ្តល់ព័ត៌មានបន្ថែមជូនដល់សាធារណជន ដែលមានបំណងចូលរួមសិក្សាស្វែងយល់អំពីស្តង់ដាខាងលើតែមិនទាន់បានចុះឈ្មោះនៅឡើយអាចធ្វើការចុះឈ្មោះបាន។

ក្នុងន័យនេះ **និយ័តករគណនេយ្យនិងសវនកម្ម** សូមលើកពេលវេលានៃវគ្គបណ្តុះបណ្តាលស្តីពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញទៅ **ថ្ងៃទី ២៩-៣០-៣១ ខែកក្កដា ឆ្នាំ២០២៤** វិញ។

អាស្រ័យហេតុនេះ សូមសាធារណៈជន និងសិក្ខាកាមទាំងអស់មេត្តាជ្រាបជាព័ត៌មាននិងសូមចូលរួមវគ្គបណ្តុះបណ្តាលខាងលើតាមពេលកំណត់ដូចមានខ្លឹមសារក្នុងសេចក្តីជូនដំណឹងនេះ។

**និយ័តករគណនេយ្យនិងសវនកម្ម**

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

កញ្ញា សុខ ណារី ៖០៦៩ ៥៥១ ៥០៧

លោក ឡាយ វិចិត្រ ៖០៩៥ ៧០១ ៩៧០